# សូមរៀបចំផែនការជាមុន ប្រសិនបើអ្នកមានហានិភ័យខ្ពស់នៃជំងឺធ្ងន់ធ្ងរពី COVID-19 និងជំងឺគ្រុនផ្តាសាយធំ

## តើអ្នកមានហានិភ័យខ្ពស់នៃជំងឺធ្ងន់ធ្ងរពី COVID-19 និងជំងឺគ្រុនផ្តាសាយធំដែរឬទេ?

### នេះរួមមាន៖

- មនុស្សដែលមានអាយុ៦០ឆ្នាំ និងអាយុលើសនេះ
- ស្ត្រីមានផ្ទៃពោះ
- ជនជាតិដើម អ្នកកោះ Torres Strait និងប្រជាជនកោះប៉ាស៊ីហ្វិក
- អ្នកដែលមានជំងឺធាត់ ជំងឺទឹកនោមផ្អែម ជំងឺសរសៃឈាមបេះដូងធ្ងន់ធ្ងរ ជំងឺសួតរ៉ាំរ៉ៃ (រួមទាំងជំងឺហឺតធ្ងន់ធ្ងរដែលតម្រូវឱ្យចូលព្យាបាលនៅមន្ទីរពេទ្យ ក្នុងរយៈពេល១២ខែចុងក្រោយ) ជំងឺថ្លើមរ៉ាំរ៉ៃធ្ងន់ធ្ងរ ឬជំងឺតម្រងនោម ជំងឺមហារីកសកម្ម ឬអ្នកដែលមានភាពស៊ាំចុះខ្សោយ។
- មនុស្សមួយចំនួនដែលមានពិការភាព រួមទាំងជនពិការដែលប៉ះពាល់ដល់សួត បេះដូង ឬប្រព័ន្ធភាពស៊ាំរបស់ពួកគេ
- អ្នករស់នៅក្នុងមណ្ឌលថែទាំមនុស្សចាស់ និងជនពិការ
- មនុស្សដែលមានអាយុ១៨ឆ្នាំ និងអាយុលើសនេះ ដែលមិនបានចាក់វ៉ាក់សាំង។

ប្រសិនបើអ្នកឈឺ វេជ្ជបណ្ឌិតរបស់អ្នកអាចណែនាំឱ្យលេបថ្នាំប្រឆាំងវីរុស ដើម្បីជួយអ្នកឱ្យបានប្រសើរឡើង។

អ្នកនឹងចាំបាច់ត្រូវលេបថ្នាំនេះ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីអ្នកឈឺ។

សូមរៀបចំផែនការជាមុន ហើយនិយាយទៅកាន់វេជ្ជបណ្ឌិតរបស់អ្នកឥឡូវនេះ ថាតើថ្នាំប្រឆាំងវីរុសត្រូវសមនឹងអ្នកដែរឬទេ។

ប្រសិនបើអ្នកមានកង្វល់សុខភាពណាមួយ ហើយត្រូវការជំនួយផ្នែកភាសា សូមទូរសព្ទទៅ TIS តាមលេខ **131 450** ហើយស្នើសុំ NSW Health Flu និង COVID-19 Care នៅតាមបណ្តាញទូរសព្ទ Home Support Line តាមលេខ **1800 960 933**។

**សូមចូលទៅកាន់គេហទំព័រ www.nsw.gov.au សម្រាប់ព័ត៌មានបន្ថែម**


© NSW Health May 2022.